អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

# ក្រមសីលធម៌ចៅក្រម

**បុព្វកថា**

ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖

**បានឃើញ**កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់ក្តីក្រោមច្បាប់កម្ពុជា ចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តិឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣។

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមបញ្ចូលទាំងខ្លឹមសារវិសោធនកម្មដែលបានប្រកាសឱ្យប្រើជាផ្លូវការកាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤។

**បានឃើញ**ក្រមសីលធម៌ចៅក្រម ដែលបានអនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកាលពីថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧។

**បានគិតគូរ**ដល់គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីឯករាជ្យភាពរបស់តុលាការ (ឆ្នាំ ១៩៨៥)។

**បានយល់ដឹង**ពីចរិតលក្ខណៈកូនកាត់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងភាពចាំបាច់ត្រូវអនុម័តនូវក្រមសីលធម៌ ដែលចៅក្រមជាតិ និងអន្តរជាតិត្រូវអនុវត្តតាម និង ដោយបញ្ចូលនូវនិយាមជាតិ និងអន្តរជាតិ។

**បានព្រមព្រៀងគ្នា**ដូចខាងក្រោម៖

**មាត្រា ១ ៖ គោលការណ៍ឯករាជ្យភាពរបស់តុលាការ**

១. ចៅក្រមត្រូវរក្សានូវឯករាជ្យភាពនៃការិយាល័យរបស់ខ្លួន និងសិទ្ធិអំណាចរបស់ខ្លួនក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅកាត់ថា អ.វ.ត.ក) ហើយត្រូវប្រតិបត្តិតាមសិទ្ធិអំណាច និងឯករាជ្យភាពក្នុងការបំពេញតួនាទីរបស់ខ្លួន។

២. ចៅក្រមមិនត្រូវចូលរួមក្នុងសកម្មភាពណាមួយ ដែលទំនងជាជ្រៀតជ្រែកចូលក្នុងការបំពេញមុខនាទីរបស់ខ្លួន ឬអាចប៉ះពាល់ដល់ជំនឿទុកចិត្តលើឯករាជ្យភាពរបស់ខ្លួន។

**មាត្រា ២ ៖ គោលការណ៍អនាគតិ**

១. ចៅក្រមត្រូវរក្សានូវភាពមិនលម្អៀង និង ត្រូវធានាពីការបង្ហាញពីភាពមិនលម្អៀងនោះក្នុងការបំពេញមុខនាទីរបស់ខ្លួន។

២. ចៅក្រមត្រូវចៀសវាងនូវរាល់ទំនាស់ផលប្រយោជន៍ ឬ ស្ថិតក្នុងស្ថានភាពណាមួយដែលគេអាចយល់ឃើញថាមានទំនាស់ផលប្រយោជន៍កើតឡើង។

**មាត្រា ៣ ៖ គោលការណ៍សុចរិតភាព**

(អនុម័តនៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៨)

១. ចៅក្រមត្រូវប្រតិបត្តិខ្លួនដោយភាពថ្លៃថ្នូរ ដោយសីលធម៌ និង ដោយសេចក្តីសុចរិតទៀងត្រង់តាមមុខនាទីរបស់ខ្លួន ដើម្បីលើកកម្ពស់ជំនឿទុកចិត្តពីសាធារណជនលើតុលាការ។

២. ចៅក្រមមិនត្រូវទទួល ឬផ្តល់ជំនូន(កាដូ) ផលប្រយោជន៍ បុព្វសិទ្ធិ ឬរង្វាន់ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដែលគេអាចយល់បានថាកំពុងតែមានចេតនាជះឥទ្ធិពលដល់ការបំពេញមុខងារតុលាការរបស់ខ្លួន ឬឯករាជ្យភាពនៃមុខនាទីរបស់ខ្លួន។

**មាត្រា ៤ ៖ គោលការណ៍ភាពសម្ងាត់**

ចៅក្រមត្រូវគោរពនូវសារសំខាន់នៃការរក្សាភាពសម្ងាត់ ចំពោះព័ត៌មានដែលទទួលបានក្នុងការបំពេញមុខនាទីរបស់ខ្លួន និង ភាពសម្ងាត់នៃការពិភាក្សាសម្រេច។

**មាត្រា ៥ ៖ គោលការណ៍វីរយភាព**

១. ចៅក្រមត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនដោយសេចក្តីសង្វាតព្យាយាម និងប្រើសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនដើម្បីបំពេញភារកិច្ចទាំងនោះ។
២. ចៅក្រមត្រូវចាត់វិធានការសមស្របដើម្បីរក្សា និងលើកកម្ពស់ចំណេះដឹង ជំនាញ និងសមត្ថភាពផ្ទាល់ខ្លួន ដែលចាំបាច់សម្រាប់បំពេញតួនាទីរបស់ខ្លួន។
៣. ចៅក្រមត្រូវបំពេញគ្រប់តួនាទីភារកិច្ចតុលាការឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ។
៤. ចៅក្រមត្រូវចេញសេចក្តីសម្រេចរបស់ខ្លួន ដោយគ្មានការពន្យារពេលដែលមិនសមរម្យ។

## មាត្រា ៦ ៖ គោលការណ៍អាកប្បកិរិយាក្នុងដំណើរការក្តី

១. នៅក្នុងកិច្ចដឹកនាំដំណើរការក្តី ចៅក្រមត្រូវរក្សានូវសណ្តាប់ធ្នាប់ របៀបរៀបរយ រៀបចំអាកប្បកិរិយាគួរជាទីគោរព រក្សាភាពអត់ធ្មត់ និងការគួរសមចំពោះអ្នកចូលរួមទាំងអស់ ក៏ដូចជាសាធារណជនដែលមានវត្តមាន ហើយត្រូវតម្រូវឱ្យអ្នកទាំងនោះអនុវត្តដូចគ្នាដែរ។
២. ចៅក្រមត្រូវយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងលើរបៀបក្នុងការតាំងសំណួរទៅកាន់សាក្សី ឬជនរងគ្រោះ និងផ្តល់ការយកចិត្តទុកដាក់ជាពិសេសលើសិទ្ធិរបស់អ្នកចូលរួមក្នុងដំណើរការក្តី ដើម្បីឲ្យទទួលបានការការពារ និងអត្ថប្រយោជន៍ស្មើគ្នាតាមផ្លូវច្បាប់។
៣. ចៅក្រមត្រូវចៀសវាងនូវការប្រព្រឹត្ត ឬការថ្លែងណាមួយដែលមានភាពរើសអើងពូជសាសន៍ រើសអើងភេទ ឬជាការមាក់ងាយ និងតាមដែលអាចធ្វើទៅបាន ចៅក្រមត្រូវធ្វើយ៉ាងណាឱ្យអ្នកចូលរួមក្នុងកិច្ចដំណើរការនីតិវិធីចៀសវាងពីការថ្លែង ឬប្រព្រឹត្តិដូច្នេះ។

## មាត្រា ៧ ៖ គោលការណ៍សម្តែងមតិជាសាធារណៈ និងទំនាក់ទំនងជាមួយសាធារណៈ

១. ចៅក្រមត្រូវអនុវត្តសិទ្ធិក្នុងការបញ្ចេញមតិ និងចូលរួមក្នុងកិច្ចការសាធារណៈណាដែលសមស្របជាមួយនឹងមុខនាទីនៃការិយាល័យរបស់ខ្លួន ហើយដែលមិនជះឥទ្ធិពល ឬទំនងជាអាចជះឥទ្ធិពលដល់ឯករាជ្យភាព និងភាពមិនលម្អៀងរបស់តុលាការ។
២. ទោះបីចៅក្រមអាចចូលរួមដោយសេរីក្នុងការពិភាក្សាវែកញែកជាសាធារណៈលើបញ្ហាទាំងឡាយទាក់ទងនឹងបញ្ហាច្បាប់ តុលាការ ឬរដ្ឋបាលតុលាការ ចៅក្រមមិនត្រូវជូនយោបល់ណាមួយទាក់ទងនឹងសំណុំរឿងដែលរង់ចាំការកាត់សេចក្តី ហើយចៅក្រមត្រូវចៀសវាងការបញ្ចេញទស្សនៈទាំងឡាយណាដែលអាចធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់កេរ្តិ៍ឈ្មោះ និងសុចរិតភាពរបស់ អ.វ.ត.ក។

**មាត្រា ៨ ៖ គោលការណ៍សកម្មភាពក្រៅកិច្ចការតុលាការ**

១. ចៅក្រមមិនត្រូវចូលរួមក្នុងសកម្មភាពក្រៅកិច្ចការតុលាការណាមួយដែលមិនត្រូវជាមួយនឹងមុខងារតុលាការរបស់ខ្លួន ឬការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលារបស់ អ.វ.ត.ក ឬដែលអាចជះឥទ្ធិពល ឬទំនងជាអាចជះឥទ្ធិពលដល់ឯករាជ្យភាព និងភាពមិនលំអៀងរបស់ខ្លួន។

២. ចៅក្រមមិនត្រូវកាន់តួនាទីនយោបាយឡើយ។

**មាត្រា ៩ ៖ ការអនុវត្តក្រម**

១. គោលការណ៍ទាំងឡាយដែលមានចែងក្នុងក្រមនេះ ត្រូវចាត់ទុកជាសេចក្ដីណែនាំស្ដីពីបទដ្ឋានសីលធម៌ជាសារវ័ន្ត ដែលចៅក្រមត្រូវប្រកាន់ខ្ជាប់ក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

២. មិនមានអ្វីមួយក្នុងខ្លឹមសារនៃក្រមនេះដែលសំដៅកំណត់ ឬដាក់កំហិតតាមមធ្យោបាយណាមួយទៅលើឯករាជ្យភាពរបស់ចៅក្រមឡើយ។

*អនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨ និងត្រូវបានធ្វើវិសោធនកម្មនៅក្នុងកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨។*